ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.១៣៦០.សហវ..ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតវគ្គមេឃុំបុរេប្រធានសម្រាប់ឆ្នាំ២០១៥
## របស់នាយកដ្ឋានបុគ្គលិក

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិកាបេស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលកណ្តាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១ ៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម" នៅនាយកដ្ឋានបុគ្គលិក នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

**ប្រការ ២ ៖**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានបុគ្គលិក ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានបុគ្គលិក

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៥
## របស់អង្គភាពថវិការនាយកដ្ឋានបុគ្គលិក

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទានទប់បង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | | | សរុបរួម | 181,710,200,000 | 1,386,000,000 | 1,131,480,600 | 254,519,400 | 282,870,150 | 82% |
| 60 | | | ការទិញ | 680,700,000 | 480,700,000 | 226,180,600 | 254,519,400 | 56,545,150 | 47% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ថែទាំបរិបាល | 322,200,000 | 322,200,000 | 167,780,600 | 154,419,400 | 41,945,150 | 52% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 322,200,000 | 322,200,000 | 167,780,600 | 154,419,400 | 41,945,150 | 52% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 25,000,000 | 25,000,000 | 25,000,000 | - | 6,250,000 | 100% |
| | | 60031 | ស្បៀង | 25,000,000 | 25,000,000 | 25,000,000 | - | 6,250,000 | 100% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 333,500,000 | 133,500,000 | 33,400,000 | 100,100,000 | 8,350,000 | 25% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 116,000,000 | 116,000,000 | 15,900,000 | 100,100,000 | 3,975,000 | 14% |
| | | 60052 | សង្ហារឹម | 7,200,000 | 7,200,000 | 7,200,000 | - | 1,800,000 | 100% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 300,000 | 300,000 | 300,000 | - | 75,000 | 100% |
| | | 60054 | សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន | 200,000,000 | 0 | - | - | - | #DIV/0! |
| | | 60058 | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100% |
| 61 | | | សេវាកម្ម | 1,067,300,000 | 905,300,000 | 905,300,000 | - | 226,325,000 | #DIV/0! |
| | 6105 | | ការថែទាំនិងជួសជុល | 136,800,000 | 136,800,000 | 136,800,000 | - | 34,200,000 | 100% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 75,000,000 | 75,000,000 | 75,000,000 | - | 18,750,000 | 100% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 15,000,000 | 15,000,000 | 15,000,000 | - | 3,750,000 | 100% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 16,800,000 | 16,800,000 | 16,800,000 | - | 4,200,000 | 100% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 28,000,000 | 28,000,000 | 28,000,000 | - | 7,000,000 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 18,000,000 | 18,000,000 | 18,000,000 | - | 4,500,000 | 100% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 740,500,000 | 740,500,000 | 740,500,000 | - | 185,125,000 | 100% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 95,900,000 | 95,900,000 | 95,900,000 | - | 23,975,000 | 100% |
| | | 61122 | សោហ៊ុយបេសកកម្ម | 95,600,000 | 95,600,000 | 95,600,000 | - | 23,900,000 | 100% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 549,000,000 | 549,000,000 | 549,000,000 | - | 137,250,000 | 100% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 138,000,000 | - | - | - | - | #DIV/0! |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 30,000,000 | - | - | - | - | #DIV/0! |
| | | 61132 | សោហ៊ុយបេសកកម្ម | 6,000,000 | - | - | - | - | #DIV/0! |
| | | 61133 | សោហ៊ុយស្នាក់នៅ | 102,000,000 | - | - | - | - | #DIV/0! |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 24,000,000 | - | - | - | - | #DIV/0! |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 24,000,000 | - | - | - | - | #DIV/0! |
| 64 | | | បន្ទុកបុគ្គលិក | 179,962,200,000 | - | - | - | - | #DIV/0! |
| | 6401 | | លាភការនិងប្រាក់បំណាច់នៃអំណាចសាធារណៈ | 1,096,800,000 | - | - | - | - | #DIV/0! |
| | | 64014 | ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ | 282,000,000 | | | | - | #DIV/0! |
| | | 64016 | លាភការទីប្រឹក្សា | 795,600,000 | | | - | - | #DIV/0! |
| | | 64017 | លាភការបេសកជន | 9,600,000 | | | - | - | #DIV/0! |
| | | 64018 | លាភការអ្នកជំនួយការ | 9,600,000 | | | - | - | #DIV/0! |
| | 6402 | | លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | 178,590,300,000 | - | - | - | - | #DIV/0! |

| ជំពូក | គណនី | អនុគណនី | កម្មវិធីចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | គណនាន ដែលជ្រើសរើស | គណនាន ផ្ទេរឲ្យ បុរេប្រទាន | គណនាន ទូទាត់ចម្មតា | គណនានទំហំ បង្វិលផ្ទេរឲ្យ បុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ដុ | ៦=៣/២ |
| | | 64021 | បៀវត្សមូលដ្ឋាន | 173,356,900,000 | | | - | - | #DIV/0! |
| | | 64022 | ប្រាក់បំណាច់មុខងារ | 5,233,400,000 | | | - | - | #DIV/0! |
| | 6403 | | ម្ញៀនិងប្រាក់បំណាច់ផ្សេងៗ | 47,800,000 | - | - | - | - | #DIV/0! |
| | | 64032 | ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង | 41,000,000 | - | - | - | - | #DIV/0! |
| | | 64036 | ប្រាក់ឧបត្ថម្ភ និងសិក្ខាកាម | 6,800,000 | - | - | - | - | #DIV/0! |
| | 6404 | | លាភការនិងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ | 16,500,000 | - | - | - | - | #DIV/0! |
| | | 64041 | បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា | 3,400,000 | | | - | - | #DIV/0! |
| | | 64043 | បៀវត្សមូលដ្ឋាន បុគ្គលិកអណ្តែត | 13,100,000 | | | - | - | #DIV/0! |
| | 6405 | | ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ | 91,500,000.00 | - | - | - | - | #DIV/0! |
| | | 64051 | មន្ត្រីមានជំងឺ | 2,000,000 | | | - | - | #DIV/0! |
| | | 64052 | អ្នកសំរាលកូន | 3,600,000 | | | - | - | #DIV/0! |
| | | 64053 | មរណភាព | 16,500,000 | | | - | - | #DIV/0! |
| | | 64054 | ឧបត្ថម្ភនិវត្តជន | 51,400,000 | | | - | - | #DIV/0! |
| | | 64055 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | 6,000,000 | | | - | - | #DIV/0! |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារ និងទុព្វលភាព | 12,000,000 | | | - | - | #DIV/0! |
| | 6406 | | ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ | 119,300,000.00 | - | - | - | - | #DIV/0! |
| | | 64061 | កូនមានអាយុក្រោម ១៥ឆ្នាំ | 66,000,000 | | | - | - | #DIV/0! |
| | | 64062 | កូនរៀនអនុវិទ្យាល័យ វិទ្យាល័យ | 17,300,000 | | | - | - | #DIV/0! |
| | | 64063 | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 36,000,000 | | | - | - | #DIV/0! |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី៣១ ខែ.កញ្ញា ឆ្នាំ២០១៥
ក. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

ម៉ិញ បានសុវណ្ណអាទិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥
ជ.អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា

ប៊ូ ច័ន្ទបូរ៉ា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥
ប្រធាននាយកបុគ្គលិក

ទៀង សុផុន

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥
រដ្ឋលេខាធិការបុរេប្រទាន

ព្រិញ គុច

បានឃើញ និងឯកភាព
ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥
រដ្ឋមន្ត្រី
ក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន